**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១១៣៣ សហវ-ឯស

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែមីនា ឆ្នាំ ២០១១

**ជម្រាបជូន**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក**

**នៃអគ្គនាយកដ្ឋានរតនាគារជាតិ**

**កម្មវត្ថុ:** សំណើសុំបុរេប្រទានថវិកាជំពូក ២១ « គម្រោងវិនិយោគផ្ទាល់» ជូននាយកដ្ឋានវិស្វកម្ម ក្រសួងធនធានទឹកនិងឧតុនិយម សម្រាប់ការងារស្តារប្រឡាយរងប្រព័ន្ធស្រោចស្រពលាំងជ្រៃខាងជើង ស្ថិតក្នុងឃុំញ្ញាយ ស្រុកសំពងទង ខេត្តកំពង់ស្ពឺ ។

**យោង:** - ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១១ លើលិខិតលេខ ៧៩១២ សហវ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

- លិខិតលេខ ០៤៥ ធទឧ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១១ របស់ក្រសួងធនធានទឹក និងឧតុនិយម ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ សូមជម្រាបឯកឧត្តមប្រតិភូជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រេចអនុញ្ញាតឲ្យក្រសួងធនធានទឹកនិងឧតុនិយម បុរេប្រទានថវិកាជំពូក ២១ « គម្រោងវិនិយោគផ្ទាល់» ចំនួន ១.៧០០.០០០.០០០រៀល (មួយពាន់ប្រាំពីររយលានរៀលគត់) ជូននាយកដ្ឋានវិស្វកម្ម ក្រសួងធនធានទឹកនិងឧតុនិយម សម្រាប់ការងារស្តារប្រឡាយរងប្រព័ន្ធស្រោចស្រពលាំងជ្រៃខាងជើង ស្ថិតក្នុងឃុំញ្ញាយ ស្រុកសំពងទង ខេត្តកំពង់ស្ពឺ មានដូចខាងក្រោម:

| | | |
|---|---|---|
| - ស្តារប្រឡាយរងខ្សែទី ១ (SN2-1) | ប្រវែង | ៥.២៥០ម៉ែត |
| - សាងសង់សំណង់ក្បាលប្រឡាយនាំទឹកលើប្រឡាយ (SN2-1) | ចំនួន | ១កន្លែង |
| - សាងសង់សំណង់លូជ្រុងលើប្រឡាយ (SN2-1) | ចំនួន | ៥កន្លែង |

ខ្ទង់ប្រាក់បុរេប្រទាននេះ នឹងត្រូវទូទាត់ដោយឥណទានថវិការបស់ក្រសួងធនធានទឹកនិងឧតុនិយម ដោយអាណត្តិបើកប្រាក់ឲ្យបានទាន់ពេលវេលា ។

សូមឯកឧត្តមប្រតិភូមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន**

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ក្រសួងធនធានទឹកនិងឧតុនិយម «ដើម្បីមុខការ »
- ឯកសារ-កាលប្បវត្តិ